**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២៣៨៣ ព.ណ.អ.ក.ប.ប

ថ្ងៃ អង្គារ ៤ កើត ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០

# សេចក្ដីជូនដំណឹង

**ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា** មានកិត្តិយសសូមគោរពជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ដែលប្រកបអាជីវកម្មនាំចូល ចែកចាយ និងផ្គត់ផ្គង់ ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារទាំងអស់ មេត្តាជ្រាបថា៖ ក្នុងរយៈពេលកន្លងមកនេះ **ក្រសួងពាណិជ្ជកម្ម** បានសង្កេតឃើញថា ការចរាចរផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ នៅលើទីផ្សារមួយចំនួន មិនបានអនុវត្តតាមខ្លឹមសារនៃមាត្រា ៩ ១០ ១១ ១២ នៃអនុក្រឹត្យលេខ ១៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្ដីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ (ឧបសម្ព័ន្ធ ១) និងប្រកាសរួមលេខ ០៦១ សនរប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៧ ស្ដីពីការអនុវត្តអនុក្រឹត្យស្ដីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ ដោយមិនទាន់បំពេញកាតព្វកិច្ចរបស់ខ្លួន នៅលើសំបកវេចខ្ចប់ ជាប់នឹងផលិតផលរបស់ខ្លួន ដូចជា ការបង្ហាញណែនាំអំពីវិធីប្រើផលិតផលជាភាសាខ្មែរ និងជាពិសេសពាក្យថា "**គ្មានអ្វីប្រសើរជាងការបំបៅ កូនដោយទឹកដោះម្ដាយតែមួយមុខគត់រហូតបាន ៦ខែ និងបន្តការបំបៅដោះម្ដាយរហូតបានអាយុ ២ឆ្នាំ ឬលើសឡើយ**"។

ដើម្បីលើកទឹកចិត្តឱ្យមានការបំបៅកូនដោយទឹកដោះម្ដាយ និងការធ្វើពាណិជ្ជកម្មដោយសុចរិត **ក្រសួងពាណិជ្ជកម្ម** សូមជម្រាបជូនដល់ក្រុមហ៊ុនធ្វើអាជីវកម្មនាំចូល ចែកចាយ និងផ្គត់ផ្គង់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារទាំងអស់ សូមអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារច្បាប់ និងឯកសារគតិយុត្ត ដែលកំពុងមានជាធរមាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីថ្ងៃចេញសេចក្ដីជូនដំណឹងនេះ ប្រសិនបើមន្ត្រីនៃអគ្គនាយកដ្ឋាន ក.ប.ប. នៃក្រសួងពាណិជ្ជកម្ម រកឃើញផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារប្រភេទណាមួយ មិនបានអនុវត្តតាមខ្លឹមសារ ឬមិនបានបំពេញតាមលក្ខខណ្ឌតម្រូវផ្សេងៗទៀត នៃអនុក្រឹត្យលេខ ១៣៣ និងប្រកាសរួមលេខ ០៦១ សនរប មន្ត្រីអគ្គនាយកដ្ឋាន ក.ប.ប. នៃក្រសួងពាណិជ្ជកម្ម នឹងចាត់វិធានការផ្អាកជាបណ្ដោះអាសន្ននូវការចរាចរ និងដកហូតចេញពីទីផ្សារ ឬអនុវត្តនីតិវិធីផ្សេងៗទៀត ដោយអនុលោមតាមច្បាប់ស្ដីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា ច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិជាធរមានផ្សេងៗទៀត ដោយមិនលើកលែង។

**ក្រសួងពាណិជ្ជកម្ម** នឹងបន្តសកម្មភាពការងាររបស់ខ្លួន ដោយឈរលើអណត្តិការងារតាមតួនាទី និងភារកិច្ច ហើយសង្ឃឹមជឿជាក់យ៉ាងមុតមាំលើកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងការជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ឱ្យប្រព្រឹត្តទៅបានល្អប្រសើរ និងដើម្បីផលប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល។

**សូមអរគុណ !**

សូមទាញយកឯកសារគតិយុត្តពី QR

# ឧបសម្ព័ន្ធ ១ ៖ លក្ខខណ្ឌតម្រូវមួយចំនួនដែលមានចែងក្នុងអនុក្រឹត្យលេខ ១៣៣

| លក្ខខណ្ឌតម្រូវមួយចំនួនដែលមានចែងក្នុងអនុក្រឹត្យលេខ ១៣៣ |
|---|
| ១.ត្រូវមានលិខិតអនុញ្ញាតរបស់ក្រសួងសុខាភិបាល |
| ២.ត្រូវមានស្លាកសញ្ញាត្រឹមត្រូវ |
| ៣.ត្រូវមានស្លាកសញ្ញាជាអក្សរខ្មែរ និងអាចអានបាន |
| ៤.ត្រូវមានអាសយដ្ឋានក្រុមហ៊ុនផលិតច្បាស់លាស់ |
| ៥.ត្រូវមានលេខឡូត៍ |
| ៦.ត្រូវមានកាលបរិច្ឆេទផុតកំណត់ប្រើប្រាស់ |
| ៧.ត្រូវមានតារាងធាតុផ្សំ |
| ៨.ត្រូវមានតារាងអាហារូបត្ថម្ភ |
| ៩.ត្រូវមានការណែនាំពីរបៀបរក្សាទុកដាក់ |
| **ទឹកដោះគោម្សៅសម្រាប់ចិញ្ចឹមទារក និងកុមារ** |
| ១០.ត្រូវមានបង្ហាញពីអាយុទារក និងកុមារ ដែលអាចប្រើប្រាស់ផលិតផលបាន |
| ១១.ត្រូវមានបង្ហាញពីផលប៉ះពាល់ទៅលើអ្នកប្រើប្រាស់នៅពេលដែលប្រើប្រាស់មិនបានត្រឹមត្រូវ |
| ១២.ត្រូវមានការណែនាំស្តីពីការប្រើប្រាស់ផលិតផល |
| ១៣.ត្រូវមានឃ្លា "គ្មានអ្វីប្រសើរជាងការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់រហូតដល់៦ខែ និងបន្តការបំបៅដោះម្តាយរហូតដល់២ឆ្នាំឬលើសឡើយ" |
| ១៤.ត្រូវមានបង្ហាញពីផលប៉ះពាល់/គ្រោះថ្នាក់នៃការប្រើប្រាស់ផលិតផលមុនអាយុ |
| ១៥.ត្រូវមានឃ្លាថា "មុនប្រើប្រាស់ត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល" |
| ១៦.ត្រូវមានឃ្លាបញ្ចុកកូនដោយប្រើពែងមានអនាម័យជាងការបំបៅដោយប្រើដប |
| ១៧. ត្រូវមានឃ្លាចង្អុលបញ្ជាក់ពីតម្លៃចំណាយសរុបសម្រាប់ចិញ្ចឹមទារកក្នុងរយៈពេល៦ខែ |
| ១៨.មិនត្រូវមានឃ្លា/ព័ត៌មានបង្កប់ន័យស្តីពីការជំរុញឱ្យប្រើប្រាស់ផលិតផលជំនួសទឹកដោះម្តាយ |
| ១៩.មិនត្រូវមានឃ្លាលើកទឹកចិត្តឱ្យប្រើប្រាស់ផលិតផលជាងការបំបៅកូនដោយទឹកដោះម្តាយ |
| **ដបបំបៅ ក្បាលដោះជ័រ និងប្រដាប់ជញ្ជក់លេង** |
| ២០.ត្រូវមានឃ្លាបង្ហាញពីឧត្តមភាពនៃការចិញ្ចឹមកូនដោយទឹកដោះម្តាយ |
| ២១.ត្រូវមានឃ្លាការបញ្ចុកទារកដោយប្រើពែងមានសុវត្ថិភាពជាងការបំបៅដោយដប |
| ២២.ត្រូវមានរូបភាព ឬអត្ថបទណែនាំត្រឹមត្រូវអំពីការប្រើប្រាស់ដបបំបៅ ក្បាលដោះ |
| ២៣.ត្រូវមានសេចក្តីណែនាំអំពីការលាងសំអាតដប និងក្បាលដោះជញ្ជក់ និងសម្ភារៈក្មេងជញ្ជក់លេង |
| **ចំពោះផលិតផលផ្អែម ឬទឹកដោះគោផ្អែម និងប្រហាក់ប្រហែលផ្សេងទៀត** |
| ២៤.ត្រូវមានឃ្លាព្រមានថាផលិតផលនេះនឹងមិនត្រូវបានប្រើសម្រាប់ទារក និងកុមារតូចៗឡើយ |

**ចំណាំ៖**

- ✓ លេខ ១ ដល់ ១៧ ជាឃ្លាដែលអនុក្រឹត្យលេខ ១៣៣ អនក្រ.បក តម្រូវឱ្យមាន (ចំពោះផលិតផលទឹកដោះគោម្សៅសម្រាប់ចិញ្ចឹមទារក និងកុមារ)
- ✓ លេខ ១៨ និង ១៩ ជាឃ្លាដែលអនុក្រឹត្យលេខ ១៣៣ អនក្រ.បក មិនតម្រូវឱ្យមាន (ចំពោះផលិតផលទឹកដោះគោម្សៅសម្រាប់ចិញ្ចឹមទារក និងកុមារ)
- ✓ លេខ ២១ ដល់ ២៤ ជាឃ្លាដែលអនុក្រឹត្យលេខ ១៣៣ អនក្រ.បក តម្រូវឱ្យមាន (ចំពោះដបបំបៅ និងផលិតផលផ្អែម ឬទឹកដោះគោផ្អែម និងប្រហាក់ប្រហែលផ្សេងទៀត)។

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម